**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ : ២៣៤/១៦ សរ.ភត.៥

# ដីកា

## ស្តីពី

## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានីភ្នំពេញ

### អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/០៦/១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៣/៣៤៥ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៣ ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងលិខិតលេខ ១៥២០ ស.ជ.ណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ
- យោងភារកិច្ចចាំបាច់ចំពោះមុខ

### សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **ប៉ា** | **សុជាតិវង្ស** | **អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** | **ប្រធាន** |
| ២-ឯកឧត្តម | **ឃួង** | **ស្រេង** | អភិបាលរងរាជធានីភ្នំពេញ | អនុប្រធាន |
| ៣-លោក | **មាន** | **ចាន់យ៉ាដា** | នាយករដ្ឋបាលសាលារាជធានីភ្នំពេញ | អនុប្រធាន |



៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | |
|---|---|---|---|
| ៤-លោក | មៅ គីមថេង | ប្រធានមន្ទីរមុខងារសាធារណៈរាជធានីភ្នំពេញ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-លោក | ហួត ហៃ | នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ | សមាជិក |
| ៦-លោក | ឃុន វណ្ណា | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ៧-លោក | សួរ ផាន់ណារ៉ា | នាយកទីចាត់ការរដ្ឋបាល | សមាជិក |
| ៨-លោក | ហុក ហួលីម | នាយកទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស | សមាជិក |
| ៩-លោក | អ៊ុក សុផល | នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១០-លោកស្រី | ច័ន្ទ សុគន្ធា | នាយកទីចាត់ការអន្តរវិស័យ | សមាជិកា |
| ១១-លោក | ស៊ិន បូណិមី | នាយកទីចាត់ការរៀបចំក្រុង | សមាជិក |
| ១២-លោក | មៅ កុលម៉ារឌី | នាយកទីចាត់ការគ្រប់គ្រងកាកសំណល់ | សមាជិក |
| ១៣-លោក | យុត ឡុងឌី | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ១៤-លោក | ប៊ុត សារ៉េត | ប្រធានអង្គភាពលទ្ធកម្ម | សមាជិក |
| ១៥-លោក | វ៉ា សុធា | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីភ្នំពេញ | សមាជិក |
| ១៦-លោក | កែ ប៊ុនឡេង | ប្រធានរតនាគាររាជធានីភ្នំពេញ | សមាជិក |
| ១៧-លោក | គួច ចំរើន | អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ | សមាជិក |
| ១៨-លោក | ឃ្លាំង ហួត | អភិបាល នៃគណៈអភិបាលខណ្ឌជ្រោយចង្វារ | សមាជិក |
| ១៩-លោក | សុខ សម្បត្តិ | អភិបាល នៃគណៈអភិបាលខណ្ឌព្រែកព្នៅ | សមាជិក |
| ២០-លោក | ព្រុំ សំខាន់ | អភិបាល នៃគណៈអភិបាលខណ្ឌចំការមន | សមាជិក |
| ២១-លោក | អ៊ាង ស៊ីផាន | អភិបាល នៃគណៈអភិបាលខណ្ឌច្បារអំពៅ | សមាជិក |
| ២២-លោក | នុត ពុធដារ៉ា | អភិបាល នៃគណៈអភិបាលខណ្ឌដង្កោ | សមាជិក |
| ២៣-លោក | ឯក យុនដឿន | អភិបាល នៃគណៈអភិបាលខណ្ឌទួលគោក | សមាជិក |
| ២៤-លោក | ពេជ្រ កែវមុនី | អភិបាល នៃគណៈអភិបាលខណ្ឌមានជ័យ | សមាជិក |
| ២៥-លោក | ហែម ដារិទ្ធ | អភិបាល នៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ | សមាជិក |
| ២៦-លោក | លឹម សុភា | អភិបាល នៃគណៈអភិបាលខណ្ឌ៧មករា | សមាជិក |
| ២៧-លោក | ជា ពិសី | អភិបាល នៃគណៈអភិបាលខណ្ឌឫស្សីកែវ | សមាជិក |
| ២៨-លោក | ប៊ីល កុសល | អភិបាល នៃគណៈអភិបាលខណ្ឌសែនសុខ | សមាជិក |
| ២៩-លោក | មុំ វីរវស្សី | អនុប្រធានមន្ទីរមុខងារសាធារណៈរាជធានីភ្នំពេញ | មន្ត្រីបង្គោល |
| ៣០-លោក | វ៉ាន់ សារុន | ប្រធានការិយាល័យក្របខ័ណ្ឌ និងបណ្តុះបណ្តាល | មន្ត្រីបង្គោល ។ |

**ប្រការ២.-**

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ថ្នាក់ក្រោមជាតិ
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ថ្នាក់ក្រោមជាតិ ជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់សាធារណៈ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦៦៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានីភ្នំពេញ
- រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពឱ្យបានទៀងទាត់រៀងរាល់**ត្រីមាស** មកលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ជូនក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ ដើម្បីធ្វើរបាយការណ៍ជូន **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជ្រាប និងផ្តល់គោលការណ៍ណែនាំអនុវត្ត
- ផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈមន្ត្រីបង្គោល ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីកានេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.-**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលគ្រប់ខណ្ឌ ប្រធានមន្ទីរ-អង្គភាពជំនាញជុំវិញសាលារាជធានីភ្នំពេញ នាយកទីចាត់ការ-ប្រធានអង្គភាពលទ្ធកម្មចំណុះរចនាសម្ព័ន្ធរដ្ឋបាលរាជធានីភ្នំពេញ និងសាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តដីកានេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦**

**អភិបាលរាជធានីភ្នំពេញ**

**ប៉ា សុជាតិវង្ស**

***កន្លែងទទួល៖***
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- លេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សារាជធានីភ្នំពេញ
- **ដូចប្រការ៤**
- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh